# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាជាមួយអដ្ឋិធាតុរបស់សន្ត លូវីស និងសន្តី ហ្សេលី ម៉ាតាំង
# ជុំគិរី ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩
## សេចក្ដីស្រឡាញ់នៅក្នុងក្រុមគ្រួសារ

**អត្ថបទទី១៖ ថេស្សាឡូនិក ទី១ ២,៩-១៣**

បងប្អូនក៏ជ្រាបថា យើងបានប្រព្រឹត្តចំពោះបងប្អូនម្នាក់ៗ ដូចឪពុកប្រព្រឹត្តចំពោះកូនដែរ។ ១ ថស ២,១១

**ដំណឹងល្អ៖ ម៉ាថាយ ២៣,២៧-៣២**

អ្នករាល់គ្នាសម្ដែងឫកពារខាងក្រៅឲ្យមនុស្សម្នាឃើញថា អ្នករាល់គ្នាសុចរិត តែចិត្តអ្នករាល់គ្នាពោរពេញដោយគំនិតលាក់ពុត និងគំនិតទុច្ចរិតទៅវិញ។ មថ ២៣,២៨

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ សម្រាប់ព្រះសហគមន៍យើង ជាពិសេសសម្រាប់ក្រុមគ្រួសារ ជាពេលវេលាដែលយើងពោរពេញដោយអំណរ ដោយសារយើងដឹងថានៅទល់មុខយើងមានធាតុរបស់សន្តសន្តីដែលជាប្ដីប្រពន្ធ ដែលជាអ្នកដ៏វិសុទ្ធ។ ទីនេះមានកោដ្ឋ ដែលនៅក្នុងកោដ្ឋនេះមានធាតុ ជាឆ្អឹងដែលគេយកមកពីដីនៅពេលគេកប់ ដោយសារ ហ្សេលី គាត់ស្លាប់នៅឆ្នាំ១៨៧៧ និង លូវីសស្លាប់នៅឆ្នាំ១៨៩៤។ ព្រះសហគមន៍ បានទទួលស្គាល់អ្នកទាំងពីរជាអ្នកដ៏វិសុទ្ធនៅឆ្នាំ២០០៨ និងទទួលស្គាល់ជាសន្តសន្តីនៅឆ្នាំ២០១៥។

ថ្ងៃនេះ នៅពេលយើងទទួលឪពុកម្ដាយសន្តីតេរេសា ដើម្បីដឹងថានេះជាវត្តមានរបស់ប្ដីប្រពន្ធមួយគូដែលជាគំរូសម្រាប់ជីវិតរបស់យើងជាគ្រីស្តបរិស័ទ ដែលធ្វើដំណើរនៅលើពិភពលោកនេះ។ ថ្ងៃនេះ ខ្ញុំចង់បង្ហាញថាប្ដីប្រពន្ធនេះជាប្ដីប្រពន្ធដែលជាគ្រួសារដ៏វិសុទ្ធ ទោះបីរស់នៅ១៥០ឆ្នាំមុនក៏មានអត្ថន័យដ៏ល្អបំផុតសម្រាប់យើងបច្ចុប្បន្ននេះ។ ដោយសារ ជីវិតគ្រួសារពីដើមរៀងមកព្រះជាម្ចាស់បានបង្កើតអាដាំនិងអេវ៉ាជាប្ដីប្រពន្ធដំបូង ក្រោយមកអាដាំនិងអេវ៉ាបានកូន (កាអ៊ីន អាបិល និងសិត)។ គ្រួសារជាមូលដ្ឋាននៃសង្គមនីមួយៗ សព្វថ្ងៃយើងមានរាប់លានគ្រួសារដែលណែនាំឲ្យពិភពលោករបស់យើង មានសង្គមដែលពោរពេញដោយជីវិត ដោយសារពេលប្ដីប្រពន្ធរៀបការហើយមានកូន។ ដូច្នេះ ថ្ងៃនេះយើងបានទទួលប្ដីប្រពន្ធដែលបានមានកូន៩នាក់ នៅក្នុងកូន៩នាក់នេះមានកូន៤នាក់ដែលស្លាប់ ម្នាក់ស្លាប់ពេលអត់ទាន់កើត ពីរនាក់ស្លាប់ពេលនៅក្មេងខ្ចី និងម្នាក់ស្លាប់នៅពេលអាយុ៥ឆ្នាំ។ ដោយសារនៅសម័យមានបញ្ហាថ្នាំ មានបញ្ហាសុខភាព មានបញ្ហាគ្រូពេទ្យ មានបញ្ហាមណ្ឌលសុខភាព មានបញ្ហាច្រើនដូច្នេះគ្រួសារនេះបានបាត់កូនអស់បួននាក់។ ប៉ុន្តែ នៅសល់កូនស្រីប្រាំនាក់ទៀត ដែលនៅរស់ទាំងប្រាំនាក់បាន

សុំទៅជាអ្នកបួស មានបួននាក់ចូលនៅក្នុងអារាមសម្ងាត់កាលម៉ែល និងម្នាក់ចូលនៅក្នុងក្រុមគ្រួសារមួយទៀត។

គ្រួសារនេះ ជាក្រុមគ្រួសារមួយប្លែកម្យ៉ាង លូវីស ដែលជាឪពុកនៅពេលនៅក្មេងគាត់គិតតែចង់ធ្វើជាបូជាចារ្យ ដូច្នេះគាត់ចូលនៅក្នុងទេវវិទ្យាល័យតូចដើម្បីត្រៀមខ្លួនធ្វើជាបូជាចារ្យ តែគេឃើញគាត់រៀនមិនសូវឆ្លាតដូច្នេះគេថាមិនអាចធ្វើបូជាចារ្យបានទេ គេឲ្យគាត់ចេញពីទេវវិទ្យាល័យ។ ហ្សឺលី ដែលជាម្តាយគាត់ចង់តែធ្វើបងស្រី ពេលគាត់ចូលនៅក្នុងសាលាដូនជីដើម្បីត្រៀមខ្លួនធ្វើដូនជី ប៉ុន្តែប្រធានបងស្រីឃើញថាហ្សឺលីធ្វើដូនជីមិនបាន ដូច្នេះគេឲ្យគាត់ចេញពីក្រុមបងស្រីដែរ។ ពីរនាក់នោះ គេចាប់ផ្តើមមានជីវិតផ្ទាល់ខ្លួន លូវីស គាត់ជាជាងនាឡិកា និង ហ្សឺលី គាត់ជាជាងប៉ាក់ មានថ្ងៃមួយគេដើរលើស្ពានមួយនិងជួបគ្នានៅលើស្ពាននោះ ពេលគេមើលមុខគ្នាទៅវិញទៅមកភ្លាមគេចូលនៅក្នុងរឿងស្នេហាហើយគេរៀបការ។ តាមពិតប្លែកដែរដោយសារម្នាក់ចង់ធ្វើជាបូជាចារ្យ ម្នាក់ចង់ធ្វើជាបងស្រី ជួបគ្នានៅលើស្ពានមើលមុខគ្នាស្រឡាញ់គ្នា បីខែក្រោយមកគេរៀបការ។ ក្រោយមក ចាប់ផ្តើមមានកូនច្រើនរហូតដល់ប្រាំបួននាក់។

ហ្សឺលី គាត់មានជម្ងឺមហារីកសុដន់គាត់មានអាយុ៤៦ឆ្នាំ គ្រូពេទ្យបាននិយាយថាគាត់អត់មានសង្ឃឹមទេ៦ខែក្រោយមកគាត់ស្លាប់។ នៅពេលគាត់ស្លាប់ កូនស្រីគាត់ឈ្មោះ តេរេសា មានអាយុ៤ឆ្នាំ ឪពុកគាត់យកចិត្តទុកដាក់ថែរក្សាកូនរហូតដល់គាត់ស្លាប់នៅអាយុ៧១ឆ្នាំ ដោយសារគាត់មានបញ្ហាវង្វេងស្មារតី។ ទាំងពីរនាក់នោះ ទៅជាគ្រួសារដ៏វិសុទ្ធសម្រាប់បច្ចុប្បន្ននេះ ថ្ងៃនេះយើងបានស្តាប់នៅក្នុងអត្ថបទទី១ សន្តប៉ូលបាននិយាយថា "**បងប្អូនក៏ជ្រាបថាយើងបានប្រព្រឹត្តចំពោះបងប្អូនម្នាក់ ដូចឪពុកបានប្រព្រឹត្តចំពោះកូនដែរ គឺយើងបានទូន្មាននិងលើកទឹកចិត្តបងប្អូនហើយយើងក៏បានអង្វរបងប្អូនឲ្យរស់នៅយ៉ាងសមរម្យ ដោយស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដែលបានត្រាស់ហៅបងប្អូនឲ្យមកចូលរួមនៅក្នុងព្រះរាជ្យ និងសិរីរុងរឿងរបស់ព្រះអង្គ**"។ នៅក្នុងអត្ថបទនេះ ដូចជាយើងបានសង្ខេបអំពីតួនាទីរបស់ឪពុកគឺ ទី១អប់រំកូនៗ ទី២លើកទឹកចិត្តកូនៗ និងទី៣ទូលអង្វរដើម្បីឲ្យកូនៗរស់នៅតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ នេះជាអ្វីដែល លូវីស បានយកចិត្តទុកដាក់អស់មួយជីវិត។

លូវីស គាត់ធ្លាប់និយាយថា "**ខ្ញុំប្រញាប់ដើម្បីអរព្រះគុណព្រះជាម្ចាស់ ខ្ញុំប្រញាប់ដើម្បីណែនាំឲ្យកូនៗដើម្បីអរព្រះគុណព្រះជាម្ចាស់ដែរ ដោយសារខ្ញុំជឿថាគ្រួសារយើងទោះបីជាគ្រួសារសាមញ្ញធម្មតាក៏ដោយ ក៏ជាគ្រួសារមួយមានកិត្តិយសណាស់ ដោយសារព្រះជាម្ចាស់បានជ្រើសរើសគ្រួសារយើង និងណែនាំឲ្យគ្រួសារយើងទទួលព្រះអំណោយទានយ៉ាងច្រើនពីព្រះជាម្ចាស់**"

គាត់ចេះទទួលស្គាល់។ គាត់ចង់អរព្រះគុណព្រះជាម្ចាស់ ប៉ុន្តែគាត់ណែនាំឲ្យកូនរបស់គាត់អរព្រះគុណព្រះជាម្ចាស់ គ្រួសារដ៏សុខសាន្តគឺជាគ្រួសារដែលឪពុកម្ដាយគឺចេះស្រឡាញ់គ្នាទៅវិញទៅមក។ ដោយសារមុនមានកូនគឺប្ដីប្រពន្ធដែលរៀបការ ពេលយើងរៀបការមានន័យថាយើងស្រឡាញ់គ្នា ប៉ុន្តែបន្តិចម្ដងៗពេលយើងចាស់ទៅយើងមានបញ្ហាច្រើនទៅៗ ជួនកាលពិបាកតស៊ូនៅក្នុងសេចក្ដីស្រឡាញ់របស់យើង ដោយសារភ្លេចនឹកឃើញស្នេហាដំបូង។ ប៉ុន្តែឲ្យយើងតស៊ូតស៊ូជាមួយប្ដី តស៊ូជាមួយប្រពន្ធ មិនមែនតែដំបូងគឺអស់មួយជីវិត។

នៅក្នុងគ្រួសាររបស់សន្ដី តេរេសា ឪពុកម្ដាយបានស្រឡាញ់គ្នាទៅវិញទៅមក ម្ដាយធ្លាប់សរសេរសំបុត្រទៅឪពុកពេលគាត់នៅឆ្ងាយពីគ្នាថា "**ខ្ញុំថើបបងអស់ពីដួងចិត្តរបស់ខ្ញុំ ខ្ញុំសប្បាយចិត្តណាស់ដោយសារខ្ញុំដឹងថានៅថ្ងៃនេះបងនឹងត្រឡប់មកវិញ ដូច្នេះថ្ងៃនេះខ្ញុំធ្វើការមិនកើតទេ ដោយសារសប្បាយពេក ត្រេកអរពេក ព្រោះដឹងថាបងត្រឡប់មកវិញថ្ងៃនេះ ពេលបងចេញទៅឆ្ងាយខ្ញុំប្រៀបដូចជាត្រីមួយដែលជិតអស់ទឹកហើយ ពីប្រពន្ធដែលស្រឡាញ់ប្ដីលើសពីជីវិតផ្ទាល់ខ្លួនទៀត**"។ ពេលប្ដីទៅឆ្ងាយធ្វើការដើម្បីរកស៊ី ប្រពន្ធមានអារម្មណ៍ដូចជាត្រីតូចមួយដែលចេញពីទឹកទៅរកដង្ហើមដោយសារដូចជាខ្វះភាពកក់ក្ដៅ ខ្វះសេចក្ដីស្រឡាញ់ដែលប្ដីឲ្យជារៀងរាល់ថ្ងៃ។ គាត់ថែមទៀតថា "**ពីព្រឹកដល់យប់វិញ្ញាណរបស់ខ្ញុំ ចិត្តរបស់ខ្ញុំ ភ្ជាប់ជាមួយបងមែនទែន ខ្ញុំមិនអាចរស់នៅឆ្ងាយពីបងទេ**"។ ក្រោយមកប្ដី គាត់សរសេរសំបុត្រឆ្លើយតបថា "**ខ្ញុំមានអារម្មណ៍ពេលវេលាដើរយឺតណាស់ដោយសារយើងនៅឆ្ងាយពីគ្នា ខ្ញុំទន្ទឹងរង់ចាំមែនទែនដើម្បីជួបអូនវិញ ពីប្ដីដែលជាមិត្តសម្លាញ់ដ៏ពិសេសរបស់អូន ដែលស្រឡាញ់សម្រាប់អស់មួយជីវិត**" តើយើងចេះសរសេររបៀបនេះដល់ប្ដីប្រពន្ធយើងសព្វថ្ងៃឬទេ? នេះជារបៀបដែលពីរនាក់បានថែរក្សាសេចក្ដីស្រឡាញ់រវាងប្ដីនិងប្រពន្ធ អត់ទាន់គិតពីកូនទេតែអ្វីសំខាន់គឺប្ដីប្រពន្ធភ្ជាប់គ្នា ទោះបីនៅឆ្ងាយពីគ្នាក៏ដោយ ទោះបីនៅជិតគ្នាក៏ដោយ ទោះបីមានបញ្ហានៅក្នុងជីវិតក៏ដោយ ទោះបីធ្លាក់ទឹកចិត្តក៏ដោយ អាចលើកទឹកចិត្តគ្នាទៅវិញទៅមកដើម្បីធ្វើដំណើរតទៅទៀត នេះជាសេចក្ដីស្រឡាញ់រវាងប្ដីនិងប្រពន្ធ។

សេចក្ដីស្រឡាញ់រវាងឪពុកម្ដាយចំពោះកូន និងសេចក្ដីស្រឡាញ់រវាងកូននិងកូនដែរ គ្រួសារសុខសាន្តគឺប្ដីប្រពន្ធចេះសម្រុះសម្រួល ចេះអធ្យាស្រ័យ ចេះធ្វើដំណើរទៅមុខទោះបីមានបញ្ហាក៏ដោយ និងបង្កើតបរិយាកាសមួយយ៉ាងពិសេសនៅក្នុងក្រុមគ្រួសារ ដើម្បីឲ្យកូនមានភាពកក់ក្ដៅដោយទទួលសេចក្ដីស្រឡាញ់ពីឪពុកម្ដាយ។ ពេលខ្ញុំនៅក្មេង ឪពុកខ្ញុំម្ដងៗចេញធ្វើដំណើរមួយថ្ងៃមួយយប់ ពេលឪពុកខ្ញុំអត់ត្រឡប់មកវិញពេលយប់ម៉ោងហូបបាយ ជាមួយម្ដាយខ្ញុំនិងប្អូនស្រីខ្ញុំ បីនាក់ដូចជាខ្វះភាពកក់ក្ដៅអស់ហើយ។ ហ្សឺលីន ដែលជាកូនធ្លាប់សរសេរសំបុត្រ

អំពីឪពុកគាត់ថា "**ដួងចិត្តរបស់គាត់ បេះដូងរបស់គាត់ ចេះតែស្រឡាញ់យើងយ៉ាងពិសេសបំផុត គាត់រស់នៅតាមរយៈយើងជានិច្ច អត់មានយើងប្រៀបដូចជាគាត់អស់ហើយ ឪពុកប្រៀបដូចជាមានសេចក្តីស្រឡាញ់ មានដួងចិត្តដូចម្តាយ ដែលមិនអាចមានលើសពីនេះទៀតនៅលើផែនដីនេះ**" ពេលនោះម្តាយគាត់ស្លាប់ហើយ មានតែឪពុកដែលថែរក្សាកូនទាំងប្រាំនាក់។ ដូច្នេះគាត់នឹកឃើញឪពុកគាត់ មានដួងចិត្តប្រៀបដូចម្តាយ អត់ដែលបង្ហាញការបាក់ទឹកចិត្ត អត់បង្ហាញភាពទន់ខ្សោយ ប៉ុន្តែខិតខំណែនាំឲ្យគ្រួសាររបស់គាត់រស់នៅក្នុងសេចក្តីស្រឡាញ់។ គាត់សរសេរថែមទៀតថា "**សេចក្តីស្រឡាញ់ដែលយើងមាននៅក្នុងគ្រួសារយើង បីដូចជាយើងកំពុងស្គាល់ យើងកំពុងតែសម្លឹងមើលសេចក្តីស្រឡាញ់ដែលព្រះជាម្ចាស់មានចំពោះយើង និងសម្លឹងមើលសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់**"។ នៅក្នុងក្រុមគ្រួសារដែលឪពុកម្តាយចេះស្រឡាញ់គ្នា ចេះសម្របសម្រួលគ្នា នៅក្នុងគ្រួសារដែលឪពុកម្តាយយកចិត្តទុកដាក់ជាមួយកូន និងកូនៗចេះស្រឡាញ់គ្នាដែលជាបងប្អូនបង្កើតពិតៗ ណែនាំឲ្យយើងមើលឃើញផ្ទាល់ភ្នែកអំពីសេចក្តីស្រឡាញ់ដែលព្រះជាម្ចាស់មានចំពោះយើង។ នេះ ជាការអស្ចារ្យដែលយើងបានមើលឃើញដែលគ្រួសារសន្តី តេរេសា បានមើលឃើញ។ ទំនាក់ទំនងរវាងព្រះជាម្ចាស់នឹងយើង គឺចងសម្ពន្ធមេត្រី ដូចយើងឃើញនៅលើកោដ្ឋនេះមានចិញ្ចៀនពីរវង់ ជាសញ្ញាសម្គាល់នៃសេចក្តីស្រឡាញ់រវាងប្តីនិងប្រពន្ធ ជាសម្ពន្ធមេត្រីរវាងប្តីនិងប្រពន្ធដែលបាក់បែកគ្នាមិនបានទេ ហើយជាសម្ពន្ធមេត្រីរវាងព្រះជាម្ចាស់និងយើងដែរ។ ចិញ្ចៀននេះ សំខាន់ណាស់ដោយសារនឹកឃើញដល់ថ្ងៃដែលយើងរៀបការ ជាឱកាសមួយដ៏ល្អកុំឲ្យយើងភ្លេចនឹកឃើញជីវិតដែលយើងមានពីដើម ដើម្បីនឹកឃើញសេចក្តីស្រឡាញ់ដែលយើងមានពីដើម ដើម្បីឃើញសេចក្តីស្រឡាញ់រវាងគ្នានិងគ្នា និងសេចក្តីស្រឡាញ់ដែលព្រះជាម្ចាស់មានសម្រាប់យើង។

តេរេសា បានរកឃើញផ្លូវមួយដែលណែនាំឲ្យយើងរកឃើញសេចក្តីសុខជាមួយព្រះជាម្ចាស់ គឺព្រះយេស៊ូផ្ទាល់ដែលជាផ្លូវ។ ពេលយើងទុកឲ្យព្រះយេស៊ូចាប់ដៃយើង ព្រះយេស៊ូណែនាំឲ្យយើងឡើងស្ថានបរមសុខ។ នៅសម័យសន្តី តេរេសា មានជណ្តើរយន្តហើយគាត់នឹកឃើញព្រះយេស៊ូក៏ដូចគ្នាដែរ ប្រសិនបើខ្ញុំចង់ឡើងស្ថានបរមសុខខ្ញុំមិនរើសផ្លូវពិបាកទេ ចាប់ដៃព្រះយេស៊ូព្រះអង្គជួយឲ្យខ្ញុំឡើងទៅលើតែម្តង។ សន្តី តេរេសា រកឃើញនេះដោយសារសន្តី តេរេសា មានបទពិសោធន៍នៅក្នុងសេចក្តីស្រឡាញ់ពីឪពុកម្តាយ ដែលបានស្រឡាញ់គាត់របៀបប្លែកនិងសេចក្តីស្រឡាញ់នេះគាត់បានយល់ថានេះ ជាសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់សម្រាប់គាត់។

ហ្សីលី ជីវិតពេលគាត់នៅក្មេងពិបាកមែនទែន គាត់រស់នៅក្នុងគ្រួសារក្រីក្រហើយម្តាយអត់ចូលចិត្តគាត់ទេ ម្តាយអត់ស្រឡាញ់គាត់សោះ ម្តាយអត់មើលគាត់ ពេលគាត់នៅក្មេងគាត់អត់

ដែលស្គាល់ភាពកក់ក្ដៅពីឪពុកម្ដាយ អត់ដែលស្គាល់ការលើកទឹកចិត្តពីឪពុកម្ដាយសោះ។ ប៉ុន្តែនៅពេលគាត់ទៅជាម្ដាយ គាត់មិនធ្លាក់ទឹកចិត្តផ្ទុយទៅវិញគាត់យកចិត្តទុកដាក់ ដើម្បីឲ្យកូននិងប្ដីរបស់គាត់ស្គាល់សេចក្ដីស្រឡាញ់ពិតប្រាកដ។ បទពិសោធន៍របស់គាត់ផ្ទុយពេលគាត់នៅក្មេង តែពេលគាត់រៀបការហើយ គាត់ខិតខំឲ្យកូនគាត់មានភាពកក់ក្ដៅ និងសេចក្ដីស្រឡាញ់ដែលគាត់ប្រគល់ឲ្យកូន ណែនាំឲ្យសន្តិ តេរេសា យល់យ៉ាងច្បាស់អំពីសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់។

សរុបសេចក្ដី គ្រួសារដ៏វិសុទ្ធដែលនៅទីនេះគឺជាគ្រួសារទំនើបសម្រាប់បច្ចុប្បន្ននេះ ដែលប្ដីប្រពន្ធចេះស្រឡាញ់គ្នាទៅវិញទៅមក ប្ដីប្រពន្ធចេះស្រឡាញ់កូនអស់ពីដួងចិត្ត និងណែនាំឲ្យកូនចេះស្រឡាញ់គ្នាទៅវិញទៅមក។ ថ្ងៃនេះ យើងអធិដ្ឋានសម្រាប់គ្រួសារយើងទាំងអស់ ដើម្បីឲ្យយើងយកកម្លាំងកាយកម្លាំងចិត្តដើម្បីតស៊ូទៅមុខ ដើម្បីមានសេចក្ដីសង្ឃឹមជានិច្ច ដើម្បីឲ្យគ្រួសាររបស់យើងបន្តិចម្ដងៗ អាចកសាងសេចក្ដីនៅក្នុងសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់។ អាម៉ែន៕